រដ្ឋបាលជលផល



# ការចិញ្ចឹមត្រីអណ្តែងជាលក្ខណៈគ្រួសារ

ចូរប្អូនៗសិស្សានុសិស្ស យុវជនទាំងអស់ នៅជនបទស្រុកស្រែចំការចូលរួមចំណែកអោយបានសកម្មក្នុងការចិញ្ចឹមត្រីនៅពេលទំនេរក្រៅម៉ោងសិក្សារៀនសូត្រ ដើម្បីជាប្រយោជន៍ជួយជំនួយដៃជើងពុកម៉ែ និងបង្កើតប្រាក់ចំណូល បន្ថែមក្នុងគ្រួសារដែលជាប្រការមួយប្រសើរជាងការប្រព្រឹត្តអំពើខុសច្បាប់ក្រៅសង្គម ប្រើប្រាស់គ្រឿងញៀន បណ្តាលអោយខូចសុខភាព និងគ្រោះថ្នាក់បាត់បង់ជីវិត ដែលសង្គមស្អប់ខ្ពើម ។

# ការចិញ្ចឹមត្រីអណ្ដែង
# ជាលក្ខណៈគ្រួសារ

កែសម្រួលដោយ :
**នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម**

ឧបត្ថម្ភបោះពុម្ពឡើងវិញដោយ :
**នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ នៃរដ្ឋបាលជលផល**
**ឆ្នាំ ២០០៩**

The project "**Strengthening the Fisheries Administration's Gender Strategy of Cambodia, and its implementation in Stung Treng and Ratanakiri provinces, 11-PR1-0795**" funded by AECID (Spanish Agency for International Development Cooperation), modification of some draws and pictures in order to mainstream gender. The text has not suffered and change.

គម្រោង "**ការពង្រឹងយុទ្ធសាស្ត្រយេនឌ័ររបស់រដ្ឋបាលជលផលនៅកម្ពុជា និងការអនុវត្តន៍គម្រោងក្នុងខេត្តស្ទឹងត្រែង និងខេត្តរតនះគីរី 11-PR1-0795**" ឧបត្ថម្ភថវិកាដោយ AECID (ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ នៃប្រទេសអេស្ប៉ាញ) បានបោះពុម្ពឡើងវិញ (ដោយមានការយល់ព្រម និងចូលរួមពីស្ថាប័នរដ្ឋបាលជលផល) នូវឯកសារនេះ បន្ទាប់ពីបានកែសម្រួលដោយប្តូរនូវរូបភាពគំនូរ និងរូបភាពថតជាក់ស្តែងមួយចំនួន ដើម្បីជម្រុញការបញ្រ្ជាបសកម្មភាពយេនឌ័រ ។ ខ្លឹមសារអត្ថបទត្រូវបានរក្សាទុកដោយមិនមានការផ្លាស់ប្តូរទេ ។

# មាតិកាអត្ថបទ

ទំព័រ

សេចក្តីថ្លែងអំណរគុណ ............................................................ ខ
សេចក្តីផ្តើម ............................................................ ឃ
១.ការជ្រើសរើសទីតាំងជីកស្រះ ............................................................ ១
២.របៀបជីកស្រះ ............................................................ ២
៣.ការរៀបចំស្រះមុនពេលដាក់កូនត្រីចិញ្ចឹម ............................................................ ៣
៤.ការលែងកូនត្រីចូលស្រះចិញ្ចឹម ............................................................ ៥
៥.កម្រិតដង់ស៊ីតេ ឬចំនួនកូនត្រីដាក់ចិញ្ចឹម ............................................................ ៦
៦.ប្រភេទចំណី និងការផ្តល់ចំណី ............................................................ ៦
៧.ការគ្រប់គ្រង និងមើលថែទាំ ............................................................ ៨
៨.វិធីការពារជំងឺ ............................................................ ៩
៩.ការប្រមូលផល (ប្រមូលផលរំលោះ និងប្រមូលផលសរុប) ............................................................ ១០
១០.ការតាមដាន និងកត់ត្រាទិន្នន័យ ............................................................ ១១
ឯកសារយោង ............................................................ ១៤

# សេចក្តីថ្លែងអំណរគុណ

ឯកសារ "**ការចិញ្ចឹមត្រីអណ្តែងជាលក្ខណៈគ្រួសារ**" នេះត្រូវបានកែសម្រួលពីឯកសារ "**ការចិញ្ចឹមត្រីអណ្តែងក្នុងស្រះ ឬអាងតូច**" ដែលរៀបរៀងដោយលោក សៀក សុលី និងការិយាល័យគាំទ្រគម្រោង នៃគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-ផ្នែកទី២ កាលពីឆ្នាំ២០០៧ ដើម្បីឆ្លើយតបទៅនឹងភាពចាំបាច់ក្នុងការផ្តល់ជាបច្ចេកទេស និងបទពិសោធន៍ដល់អ្នកសម្របសម្រួលសហគមន៍នេសាទ ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់ដែល ជួយដល់សហគមន៍នេសាទ ក្នុងការគ្រប់គ្រងធនធានធម្មជាតិឱ្យប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាពតាមរយៈការបង្កើនប្រាក់ចំណូលក្នុងគ្រួសារ។

សៀវភៅនេះ ពិតជាមានសារៈសំខាន់ដើម្បីលើកកម្ពស់សមត្ថភាព និងបច្ចេកទេស ក្នុងការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ មិនតែប៉ុណ្ណោះសៀវភៅនេះបានរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាកសិករ ជាពិសេសសមាជិកសហគមន៍ នេសាទ។

អាស្រ័យហេតុនេះ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ និងនាយកដ្ឋានវារីវប្បកម្ម នៃរដ្ឋបាលជលផលបានរៀបចំកែសម្រួលបោះពុម្ពផ្សាយឡើងវិញ ដើម្បីបំពេញតម្រូវការចាំបាច់ និងមានសារៈសំខាន់សម្រាប់ប្រជាកសិករនៅទូទាំងប្រទេសកម្ពុជា។

រដ្ឋបាលជលផល សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់អ្នកនិពន្ធ លោក **សៀក សុលី** និងក្រុមការងារការិយាល័យគាំទ្រគម្រោង និងការិយាល័យអនុវត្តន៍គម្រោងរបស់ គម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-ផ្នែកទី២ /អង្គការស្បៀងអាហារ និងកសិកម្ម អង្គការកសិកម្មសហប្រជាជាតិ (FAO) នៃធនាគារអភិវឌ្ឍន៍អាស៊ី [ADB Loan No. 1939-CAM (SF)] ។

រដ្ឋបាលជលផល សូមថ្លែងអំណរគុណដ៏ពន្លឹកដល់លោក លោកស្រីដែលជាគណៈកម្មការសហគមន៍នេសាទ និងសមាជិកសហគមន៍នេសាទ ដែលបានផ្តល់ឱកាសដល់ក្រុមការងារឈានទៅដល់សម្រេចផលិតឯកសារនេះឡើង តាមរយៈការដកស្រង់បទពិសោធន៍ជាក់ស្តែងនៅតាមមូលដ្ឋានសហគមន៍ផ្ទាល់ ។

# សេចក្តីផ្តើម

ដើម្បីរួមចំណែកជួយអភិវឌ្ឍន៍នូវចំណេះដឹងវារីវប្បកម្ម ដល់ប្រជាកសិករនៅតាមជនបទឱ្យកាន់តែមានភាពទូលំទូលាយ ពិសេសការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារក្នុងគោលដៅបង្កើនផលិតភាពត្រី វារីវប្បកម្មបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើននូវអាហារូបត្ថម្ភ បង្កើនឱកាសការងារ និងប្រាក់ចំណូលដល់ប្រជាកសិករនៅតាមជនបទក៏ដូចជាប្រជាជនកម្ពុជាទាំងមូល ។

បច្ចេកទេសស្តីពីការធ្វើវារីវប្បកម្មត្រីអណ្តែងជាលក្ខណៈគ្រួសារនឹងរួម ចំណែកលើកកម្ពស់សមត្ថភាព ផ្នែកជំនាញខ្នាតតូចជួយដល់ប្រជាកសិករឱ្យចេះ ចិញ្ចឹមត្រី ដើម្បីកាត់បន្ថយសំពាធនៃការទាញយកផលពីធនធានធម្មជាតិហួសកម្រិត ។ មិនតែប៉ុណ្ណោះឯកសារនេះនឹងរួមចំណែកជួយដល់ប្រជាកសិករកម្ពុជា ដែលមានចំណាប់អារម្មណ៍លើបច្ចេកទេសចិញ្ចឹមត្រីដែលអាចយកទៅអនុវត្តចិញ្ចឹមផ្ទាល់ដោយខ្លួនឯង និងដើម្បីប្រើប្រាស់ក្នុងការបង្រៀន ការផ្សព្វផ្សាយ ដោយផ្នែកទាំងមូលនៃឯកសារបានប្រាប់ពីជំហាននីមួយៗយ៉ាងល្អិតល្អន់ និងបង្កភាពងាយស្រួលដល់ការអនុវត្តន៍ ។

ម្យ៉ាងវិញទៀត ដោយយោងតាមតម្រូវការ និងសំណូមពរពីសំណាក់ប្រជាកសិករ និងសមាជិកសហគមន៍នេសាទ ដែលមានចំណាប់អារម្មណ៍លើបច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារទើបឯកសារស្តីពីការចិញ្ចឹមត្រីអណ្តែងនេះត្រូវបានផលិតឡើងឱ្យសមស្របទៅនឹងការអនុវត្តន៍របស់សហគមន៍នេសាទ និងប្រជាកសិករកម្ពុជាទូទាំងប្រទេស ។

ប្រភេទត្រីអណ្តែងដែលសមស្របសម្រាប់ចិញ្ចឹមជាលក្ខណៈគ្រួសារនេះ ជាប្រភេទត្រីអណ្តែងកូនកាត់ដែលផលិតចេញពីត្រីអណ្តែងអាហ្វ្រិចជាមួយត្រីអណ្តែងក្នុងស្រុក ហើយអាចបង្កាត់ភ្ញាស់បាននៅតាមស្ថានីយ៍ភ្ញាស់នានានៅក្នុងប្រទេស ។ ត្រី

អណ្ដែងកូនកាត់ នេះជាប្រភេទត្រីងាយស្រួលចិញ្ចឹម ឆាប់ធំធាត់ក្នុងរយៈពេលខ្លី ហើយឆាប់ទទួលផល ជាពិសេសបង្កលក្ខណៈងាយស្រួលដល់កសិករដែលនៅឆ្ងាយពីដែនទឹក ធម្មជាតិ ខ្វះទឹក និងពុំមានស្រះចំសម្រាប់ចិញ្ចឹម ។

## ១.ការជ្រើសរើសទីតាំងជីកស្រះ

គួរធ្វើការជ្រើសរើសទីតាំងសម្រាប់ជីកស្រះដាក់ត្រីចិញ្ចឹមឱ្យមានលក្ខណៈល្អសមស្របតាមបច្ចេកទេសពោលគឺ ស្របទៅនឹងលក្ខណៈជីវសាស្ត្រប្រភេទត្រីដែលយើងចង់ចិញ្ចឹម ។ ដោយឡែក ចំពោះប្រភេទត្រីអណ្តែង ដើម្បីចិញ្ចឹមវាឱ្យមានការលូតលាស់ធំធាត់លឿន និងទទួលបានគុណផលខ្ពស់ នោះយើងគួរតែជ្រើសរើសទីតាំងជីកស្រះឱ្យមានលក្ខណៈល្អសមស្រប និងគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោមនេះ :

- ជិតផ្ទះ ងាយស្រួលគ្រប់គ្រង និងមើលថែទាំ (ផ្តល់ចំណីគ្រប់គ្រងគុណភាពទឹក តាមដានសកម្មភាព និងសុខភាពត្រី)
- មានទីតាំងស្ថិតនៅទីវាលខ្ពស់ស្រឡះ មិនលិចទឹកនៅរដូវវស្សា ហើយមានខ្យល់ និងពន្លឺអាចចេញចូលបានល្អគ្រប់គ្រាន់
- ជាពិសេស បើអាចធ្វើបានគួរជ្រើសរើសទីតាំងជីកស្រះនៅជិតប្រភពទឹក ដើម្បីផ្តល់ភាពងាយស្រួលក្នុងការផ្លាស់ប្តូរទឹកថ្មី ក្នុងករណីចាំបាច់ ជាពិសេសនៅ ពេលត្រីពុល និងត្រីមានជំងឺ។ ម្យ៉ាងទៀតករណីយើងអាចធ្វើការផ្លាស់ប្តូរទឹកថ្មី បានញឹកញាប់ប្រមាណពី ១-២ដង ក្នុងមួយខែ គួរកម្រិតបរិមាណពីមួយភាគបី (១/៣) ទៅពាក់កណ្តាល (៥០%) នៃបរិមាណទឹកសរុបទាំងអស់ក្នុងស្រះ នោះនឹងធ្វើឱ្យត្រីធំធាត់លឿន



*រូបភាពទី១: ទីតាំងដែលមានប្រភពទឹកល្អអាចជីកស្រះចិញ្ចឹមបាន*

អាចជៀសផុតពីជំងឺបាន និងទទួលបាននូវទិន្នផលត្រីខ្ពស់ ប្រភពទឹកទាំងនេះរួមមាន: ទន្លេ បឹងបួ ត្រពាំង ស្រះ ប្រឡាយ និងអណ្តូងជាដើម ។ល។

## ២.របៀបជីកស្រះ

ទំហំដែលត្រូវជីកសម្រាប់ដាក់ត្រីអណ្តែងចិញ្ចឹមអាស្រ័យដោយលទ្ធភាពរបស់យើង ឬកសិករម្នាក់ៗអាចធ្វើបាន ពីព្រោះថាស្រះមានទំហំតូច ឬធំសុទ្ធតែចិញ្ចឹមត្រីបានទាំងអស់ ។ តែបើករណីស្រះធំពេក នោះអាចជាបញ្ហាលំបាកក្នុងការគ្រប់គ្រងជាពិសេសការគ្រប់គ្រងគុណភាពទឹក និងនៅពេលត្រីមានជំងឺ ។ នាបច្ចុប្បន្ននេះ ស្រះដែលមានលក្ខណៈសមស្របបំផុត ដែលកសិករកំពុងពេញនិយមនៅក្នុងប្រទេសកម្ពុជាយើង នោះស្រះមានទំហំចន្លោះពី ៨ម៉ែត្រការ៉េ ទៅ ២០ម៉ែត្រការ៉េ និងជម្រៅពី ៦តឹក ទៅ ១ម៉ែត្រ ហើយជីកឱ្យមានរាងជាចតុកោណកែង និងមានជើងទេរ (ក្រឡាផ្ទៃបាតស្រះតូចជាងក្រឡាផ្ទៃមាត់ស្រះខាងលើ) ដើម្បីជៀសវាងការងាយបាក់ច្រោះដីនៅតាមជញ្ជាំងស្រះ ។

ទំហំ និងលក្ខណៈស្រះមួយចំនួនដែលកសិករកំពុងពេញនិយមប្រើប្រាស់សម្រាប់ចិញ្ចឹមត្រីអណ្តែងទទួលបានលទ្ធផលល្អនោះ រួមមានដូចខាងក្រោម :

- ស្រះរាងចតុកោណកែងទំហំ: ទទឹង ២ម៉ែត្រ បណ្តោយ ៤ម៉ែត្រ ជម្រៅ ៨តឹក
- ស្រះរាងចតុកោណកែងទំហំ: ទទឹង ២ម៉ែត្រ បណ្តោយ ៥ម៉ែត្រ ជម្រៅ ៨តឹក
- ស្រះរាងចតុកោណកែងទំហំ: ទទឹង ៣ម៉ែត្រ បណ្តោយ ៦ម៉ែត្រ ជម្រៅ ១ម៉ែត្រ
- ស្រះរាងចតុកោណកែងទំហំ: ទទឹង ២ម៉ែត្រ បណ្តោយ ៤ម៉ែត្រ ជម្រៅ ៧តឹក




*រូបភាពទី២៖ របៀបជីកស្រះមានរាងជាចតុកោណកែង ឬ ចូលក្នុងជ្រុងវែង*

## ៣.ការរៀបចំស្រះមុនពេលដាក់កូនត្រីចិញ្ចឹម

ដើម្បីដំណើរការដាក់កូនត្រីចិញ្ចឹមប្រកបដោយជោគជ័យ ត្រីលូតលាស់ធំធាត់លឿន និងទិន្នផលត្រីខ្ពស់នោះ ចាំបាច់យើងត្រូវធ្វើការរៀបចំស្រះឱ្យបានស្អាតល្អជាមុន ។ ដំណើរការនៃការរៀបចំស្រះនេះដូចបានបង្ហាញជូនតាមលក្ខណៈបច្ចេកទេសខាងក្រោមនេះ ៖

- ចំពោះស្រះថ្មី ក្រោយពីជីករួចត្រូវសំអាតបាតស្រះឱ្យបានស្អាត ដើម្បីចៀសវាងការមានដុំថ្ម អំបែងកែវ មែកឈើ ឫសឈើ ដែក ដែលអាចបង្កឱ្យមានបញ្ហាដល់ការធ្លុះធ្លាយកៅស៊ូប្លាស្ទិក ក្រោយពេលក្រាល និងបញ្ចូលទឹករួច
- ចំពោះស្រះចាស់វិញ ក្រោយពីដាក់ត្រីចិញ្ចឹម និងប្រមូលផលរួច នោះយើងត្រូវបូមទឹកពង្រីងពីស្រះ លាងសំអាតកៅស៊ូប្លាស្ទិក សំអាតបាតស្រះឱ្យបានស្អាតដើម្បីចៀសវាងការមានដុំថ្ម អំបែងកែវ មែកឈើ ឫសឈើ ដែក ដែលមាន

សេសសល់អាចបង្កឱ្យមានបញ្ហាដល់ការចុះជាយកៅស៊ូប្លាស្ទិក ក្រោយពេលក្រាល និងបញ្ចូលទឹក ដើម្បីដំណើរការចិញ្ចឹមត្រីបន្តទៀត។

- បន្ទាប់ពីបានក្រាលកៅស៊ូប្លាស្ទិករួច យើងគប្បីយកភក់បាតត្រពាំង ឬបឹង មកក្រាលនៅបាតស្រះឱ្យបានកំរាស់ប្រហែលពី ០.៥-១តឹក រួចបន្ថែមលាមកសត្វស្ងួត ដូចជា គោ ជ្រូក មាន់ ឬទា អាចពង្រាយនៅបាតស្រះ ឬកម្រិតបរិមាណ ០.៥ គីឡូក្រាម ក្នុង ១ម៉ែត្រការ៉េ/ស្រះ រួចបញ្ចូលទឹកនៅដំណាក់កាលដំបូងនេះជម្រៅពី ០.២-០.៤ម៉ែត្រ ហើយត្រាំវាទុកក្នុងរយៈពេលពី៣ ទៅ ៥ថ្ងៃ ដើម្បីឱ្យជីលាមកសត្វមានប្រតិកម្មលាយ កែប្រែគុណភាពទឹកបានល្អ មានពណ៌ត្រួយចេកខ្ចី ដែលធ្វើឱ្យចំណីធម្មជាតិ កកើត លូតលាស់ មានឡើងច្រើនសម្រាប់កូនត្រីស៊ី បន្ទាប់ពីលែងចូលស្រះដំបូង។

- បន្ទាប់ពីបានបញ្ចូលទឹករយៈពេល ៤ ទៅ ៥ថ្ងៃ រួចយើងត្រូវយកដើមកំប្លោកមកត្រាំបណ្តែតលើផ្ទៃទឹក ប្រមាណ ១ភាគ ៣ នៃផ្ទៃទឹកស្រះនោះសម្រាប់ជាប្រយោជន៍ដល់កូនត្រីចូលជ្រក នៅពេលធាតុអាកាសក្តៅ ជាពិសេសពេលថ្ងៃត្រង់។

- បន្ទាប់ពីបានបញ្ចប់នូវរាល់កិច្ចការសំខាន់ៗខាងលើ នោះយើងគប្បីធ្វើរបង ឬបាំងដោយប្រើប្រាស់ស្បៃហាប៉ា និងព្រួលឫស្សីព័ទ្ធជុំវិញនៅលើភ្លឺស្រះ




*រូបភាពទី៣: ការរៀបចំស្រះមុនពេលដាក់ត្រីចិញ្ចឹម*

សម្រាប់ការពារត្រីលោតចេញ និងមាន់ ទា ក្រុកចុល ដាក់កៅស៊ូប្លាស្ទិកហែកចុះ ថ្លាយ នៅមុនពេលលែងកូនត្រីចូលស្រះចិញ្ចឹម។

## ៤.ការលែងកូនត្រីចូលស្រះចិញ្ចឹម

បន្ទាប់ពីរៀបចំស្រះបានស្អាតល្អ រួចរាល់ហើយ ដូចបានរៀបរាប់ខាងលើ នោះយើងអាចលែងកូនត្រីចូលស្រះដាក់ចិញ្ចឹមបាន។ មុននឹងលែងកូនត្រីចូលស្រះ យើងត្រូវត្រាំថង់កូនត្រីនៅក្នុងទឹកស្រះជាមុនសិន រយៈពេល ១៥ ទៅ ២០នាទី ដើម្បីធ្វើឱ្យសីតុណ្ហភាពទឹកខាងក្រៅ និងក្នុងថង់មានកម្រិតប្រហាក់ប្រហែលគ្នា និងកូនត្រីបានសម្រាកកាត់បន្ថយការនឿយហត់ក្រោយពេលដឹកជញ្ជូន។ បន្ទាប់ពីនេះ យើងអាចលែងកូនត្រីចូលស្រះចិញ្ចឹមបាន ដោយយកដៃកូរទឹកក្នុងស្រះឱ្យមានកំដៅប្រហាក់ប្រហែលគ្នានៅគ្រប់ស្រទាប់ទឹក រួចស្រាយមាត់ថង់លែងកូនត្រីចូលស្រះសន្សឹមៗ។ យើងគួរលែងកូនត្រីចូលស្រះ នៅពេលអាកាសធាតុត្រជាក់ ជាពិសេសនៅពេលព្រឹកម៉ោង ៨ ទៅ ម៉ោង ១០ ពេលមានពន្លឺព្រះអាទិត្យគ្រប់គ្រាន់ និងនៅពេលរសៀលមេឃត្រជាក់ម៉ោង ៤ ទៅម៉ោង ៥ ដែលជាពេលវេលាមានបរិមាណអុកស៊ីសែនរលាយគ្រប់គ្រាន់នៅក្នុងទឹក។



*រូបភាពទី០៤: សកម្មភាពកសិករលែងកូនត្រីចូលស្រះដាក់ចិញ្ចឹម*

## ៥. កម្រិតដង់ស៊ីតេ ឬចំនួនកូនត្រីដាក់ចិញ្ចឹម

ចំនួនកូនត្រី ឬដង់ស៊ីតេកូនត្រីដាក់ចិញ្ចឹម វាជាកត្តាសំខាន់ និងកំណត់នៃការលូតលាស់ ជំងឺ និងអត្រាងាប់ ឬអត្រារស់របស់ត្រី ហើយវាក៏ជាកត្តាមួយបង្កឱ្យកម្រិតកខ្វក់នៃទឹកកើតឡើង ដែលជាបុព្វហេតុបង្កឱ្យត្រីមានជំងឺ។ អាស្រ័យហេតុនេះ យើងគួរលែងកូនត្រីចូលស្រះចិញ្ចឹមតាមកម្រិតដង់ស៊ីតេ សមស្របមួយតាមបច្ចេកទេស ដែលចំនួនស្ថិតនៅចន្លោះពី ៤០ ទៅ ៥០ក្បាល ក្នុង ១ម៉ែត្រការ៉េ/ស្រះ ចំពោះកូនត្រីមានប្រវែងពី ៤ ទៅ ៦សង់ទីម៉ែត្រ (ប្រហែល ៣ធ្នាំងចង្អុលដៃ)។

**ឧទាហរណ៍ ៣៖** បើសិនយើងមានស្រះទំហំៈ ទទឹង ២ម៉ែត្រ បណ្ដោយ ៥ម៉ែត្រ ស្មើ ១០ម៉ែត្រការ៉េ នោះស្មើនឹងចំនួនកូនត្រីដាក់ចិញ្ចឹម ៥០០ក្បាល ក្នុងករណីយើងដាក់កូនត្រីចិញ្ចឹមចំនួន ៥០ក្បាល ក្នុង ១ម៉ែត្រការ៉េ។

## ៦.ប្រភេទចំណី និងការផ្ដល់ចំណី

### ៦.១ ប្រភេទចំណី

នៅក្នុងធម្មជាតិ ត្រីអណ្ដែងក្រោយពេលញាស់រយៈពេលបីថ្ងៃប្រើប្រាស់អស់អាហារបម្រុងនោះវានឹងចាប់ផ្ដើមស្វែងរកចំណីអាហារនៅខាងក្រៅ។ ចំណីអាហារនៅខាងក្រៅ ក្នុងធម្មជាតិដែលវាចូលចិត្តស៊ីរួមមានៈ ចៃទឹកប្រភេទដាប់ញ៉ា ម៉ូយណា កូបប៉េប៉ូដា ដង្កូវក្រហម និងពពួកសត្វល្អិតផ្សេងៗទៀតដែលរស់នៅបាតស្រះ។ ហើយនៅពេលវាធំពេញវ័យ ចូលចិត្តស៊ីចំណីចម្រុះដែលក្នុងនោះរួមមានៈ ទាំងរុក្ខជាតិ និងសត្វដែលរស់នៅក្នុងទឹក ពោលគឺវាជាប្រភេទត្រីស៊ីចម្រុះ ហើយស៊ីសាច់ជាអាហារសំខាន់។

ដោយឡែកចំពោះចំណីផ្សំ ចំពោះរុក្ខជាតិ រួមមានជាច្រើនដូចជាត្រកួន ពោត ស្លឹកដំឡូងជ្វា សណ្ដែកសៀង និងសមាសធាតុផ្សំផ្សេងៗទៀត ដូចជាកន្ទក់

ចុងអង្ករ កាកសំណល់ផ្ទះបាយ ម្សៅត្រី ឬ ត្រីងៀត។ល។ កាលសមាសធាតុចំណីទាំងនេះ យើងអាចលាយផ្សំបញ្ចូលគ្នា រួចចម្អិនឱ្យឆ្អិន ទុកឱ្យត្រជាក់មុនពេលដាក់ឱ្យត្រីស៊ី។

ចំពោះចំណីប្រូតេអ៊ីនពីជាតិសាច់រួមមាន ដូចជាពោះវៀនមាន់ ពោះវៀនត្រី កណ្ដៀវ អង្រ្កង ជន្លេន កាកសំណល់ទីសត្តឃាត និងចំណីគ្រាប់។ល។



*រូបភាពទី០៥: ប្រភេទចំណីធម្មជាតិសម្រាប់ត្រីអណ្ដែង ( ជន្លេន កណ្ដៀវ និងសត្វល្អិត ចង្រិត*



*រូបភាពទី០៦: ចំណីគ្រាប់សម្រាប់ត្រីអណ្ដែង*

## ៦.២ ការផ្ដល់ចំណី

ដើម្បីថែរក្សាសុខភាពកូនត្រីឱ្យបានល្អ នោះយើងមិនត្រូវផ្ដល់ចំណីឱ្យកូនត្រីស៊ីភ្លាមៗនោះទេ បន្ទាប់មកដឹកជញ្ជូន និងលែងចូលស្រះដាក់ចិញ្ចឹម។ យើងអាចផ្ដល់ចំណីឱ្យវាស៊ីបាននៅពេលបន្ទាប់ពីលែងចូលស្រះរយៈពេលពី ២-៣ម៉ោង នូវបរិមាណតិចបំផុត។

នៅថ្ងៃបន្ទាប់យើងអាចចាប់ផ្តើមដាក់ចំណីឱ្យកូនត្រីស៊ីតាមបច្ចេកទេសធម្មតាបាននូវបរិមាណចំណីពី ៣-៥ភាគរយ ធៀបទៅនឹងទម្ងន់ដងខ្លួនត្រីសរុបទាំងអស់នៅក្នុងស្រះ ដោយផ្តល់ឱ្យវាស៊ីចំនួនពី ២ ទៅ ៣ដងក្នុង១ ថ្ងៃ នៅពេលព្រឹកម៉ោង ៨ និងរសៀលពីម៉ោង ៤ ឬ ម៉ោង ៥។

## ៧.ការគ្រប់គ្រង និងមើលថែទាំ

ដើម្បីធានាឱ្យបាន ការចិញ្ចឹមត្រីអណ្តែងនេះ ដំណើរទៅបានល្អទទួលបានទិន្នផលខ្ពស់នោះយើងត្រូវចាំបាច់មានការយកចិត្តទុកដាក់ជាសំខាន់ទៅលើការងារគ្រប់គ្រង និងការថែទាំជាប្រចាំនូវរាល់ចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

- ត្រូវផ្តល់ចំណីឱ្យត្រីស៊ីបានគ្រប់គ្រាន់ និងទៀងទាត់ពេលវេលា
- គួរដាក់ចំណីឱ្យត្រីស៊ីបានច្រើនកន្លែង ឬទីតាំងនៅក្នុងស្រះតែមួយ
- គួរបង្ហាត់ត្រីឱ្យមានទំលាប់ដោយគោះ ឬកូរទឹកធ្វើជាសញ្ញាឱ្យត្រីចំណាំឡើងមករកចំណី
- ត្រួតពិនិត្យជាប្រចាំនូវបរិមាណចំណីដែលយើងបានផ្តល់ឱ្យត្រីស៊ីដើម្បីជៀសវាងការសល់ចំណីច្រើននៅបាតស្រះបណ្តាលឱ្យទឹកស្អុយ និងត្រីកើតជំងឺ
- ករណីពិនិត្យឃើញថា មានកាកសំណល់ចំណីសល់ធ្លាក់ចុះទៅក្នុងបាតស្រះច្រើននោះយើងត្រូវធ្វើស៊ីហ្វុង ឬបឺតកាកសំណល់ទាំងនោះចេញពីស្រះជាបន្ទាន់
- ត្រូវពិនិត្យកៅស៊ូប្លាស្ទិកជាប្រចាំ ដើម្បីជៀសវាងដាច់រហែក ធ្លុះធ្លាយធ្វើឱ្យទឹកជ្រាបចេញអស់ពីក្នុងស្រះ
- ត្រូវពិនិត្យ និងការពារកុំឱ្យដើមកំប្លោកដុះច្រើនហួសកំណត់
- បើមានលទ្ធភាព គួរធ្វើការផ្លាស់ប្តូរទឹកថ្មីជាប្រចាំនូវរៀងរាល់ ២សប្តាហ៍/ម្តងដែលយ៉ាងហោចណាស់នូវកម្រិតបរិមាណពី ៣០ ទៅ ៥០ភាគរយនៃបរិមាណ ទឹកទាំងអស់ក្នុងស្រះ។
- ជៀសវាងការចាប់ត្រីលេង ឬចាប់ត្រីមកពិនិត្យញឹកញាប់ច្រើនដង

ដែលអាចបណ្តាលឱ្យត្រីឈប់ស៊ីចំណី និងត្រីមិនធំធាត់ ។

## ៨. វិធីការពារជំងឺ

ការពារ គឺជាវិធីសាស្ត្រមួយដ៏ប្រសើបំផុត ដូចពាក្យចាស់បានពោលថា ការពារវាប្រសើរជាងព្យាបាល ។ អាស្រ័យហេតុនេះ ដើម្បីការពារជាមុន និងជៀសវាងបានពីបញ្ហាដែលបង្កឱ្យត្រីមានជំងឺ នោះយើងត្រូវមើលថែទាំ និងតាមដានសកម្មភាពត្រីជាប្រចាំ ។ ចំណុចសំខាន់ៗជាគន្លឹះមួយចំនួនដែលយើងត្រូវតែអនុវត្តធ្វើតាម នោះដូចបានបង្ហាញជូនខាងក្រោមនេះ :

- ជាពិសេស នៅពេលផ្តល់ចំណីត្រីម្តងៗ យើងត្រូវជៀសវាងកុំឱ្យចំណីសល់ច្រើននៅបាតស្រះ ដែលបង្កឱ្យទឹកស្រះខូចគុណភាពទៅជាស្អុយ ហើយបង្កបញ្ហាឱ្យត្រីកើតជំងឺបាន ។ ម្យ៉ាងវិញទៀតយើងត្រូវជៀសវាងផងដែរ ការផ្តល់ចំណីដល់ត្រីស៊ីមិនគ្រប់គ្រាន់ នោះនឹងធ្វើឱ្យខ្វះចំណីនៅក្នុងស្រះ ដែលបណ្តាលឱ្យត្រីចឹក ឬស៊ីគ្នាវា បង្កស្នាមរបួស ដំបៅ ហើយបណ្តាលឱ្យត្រីកើតជំងឺ ។

- ត្រូវតាមដាន និងគ្រប់គ្រងគុណភាពទឹកស្រះជាប្រចាំដើម្បីធានាឱ្យបានគុណភាពទឹកល្អជានិច្ច

- ត្រូវតាមដាន និងការពារកុំឱ្យមានកាកសំណល់ ឬទឹកមិនល្អហូរចូលស្រះ

- គួរប្រើទឹកមេបំបៃ ឬអ៊ីអឹម ផ្សំពីផ្លែឈើលាយបាចចូលស្រះត្រីនូវកម្រិតបរិមាណ ១០មីលីលីត្រ ក្នុង១ម៉ែត្រគូបទឹក ដើម្បីកែប្រែគុណភាពទឹក និងជួយសម្លាប់ពពួកបាក់តេរីចង្រៃពីក្នុងទឹកស្រះ បន្ថយជាតិស្អុយ នៃទឹកក្នុងស្រះចិញ្ចឹមត្រី ។

- ត្រូវត្រួតពិនិត្យផងដែរ គុណភាពកូនត្រីពូជ (សុខភាពកូនត្រីល្អ គ្មានស្នាមរបួស និងស្គាល់ប្រភពកូនត្រី នោះពិតប្រាកដ) មុនពេលលែងចូលស្រះចិញ្ចឹម ។ ចំណុចសំខាន់ៗមួយចំនួនផ្សេងទៀត ដូចបានបង្ហាញជូននៅក្នុងចំណុច ទី៧ ការគ្រប់គ្រង និងមើលថែទាំ ។

 

*រូបភាពទី០៨: ការរៀបដាក់មេអ៊ីរីមសំរែក សម្រាប់មេពោន*

## ៨.ការប្រមូលផល (ប្រមូលផលរំលោះ និងប្រមូលផលសរុប)

### ៨.១ ការប្រមូលផលរំលោះ

ជាទូទៅ ការចិញ្ចឹមត្រីអណ្តែងនៅក្នុងស្រះក្រាលកៅស៊ូប្លាស្ទិក នៅក្នុងប្រទេសកម្ពុជាយើង នាពេលបច្ចុប្បន្ននេះ កសិករចិញ្ចឹមតែក្នុងរយៈពេលខ្លីពី ២ ទៅ ៤ខែ ប៉ុណ្ណោះ និងត្រូវធ្វើការប្រមូលផលត្រីយកទៅលក់នៅលើទីផ្សារ និងប្រើប្រាស់សម្រាប់ការហូបចុកក្នុងគ្រួសារ ។

តែការប្រមូលផលរំលោះ យើងគួរចាប់ផ្តើមដំណើរការបន្ទាប់ពីបានចិញ្ចឹមរយៈពេលពី ២ទៅ ៣ខែ ជាបណ្តើរៗ ដោយចាប់រំលោះយកចេញនូវរាល់ត្រីណាដែលមានទំហំធំជាងគេសម្រាប់ហូបក្នុងគ្រួសារ និងលក់នៅលើទីផ្សារ ហើយរក្សាទុកចិញ្ចឹមបន្តត្រីដែលមានទំហំតូចៗឱ្យមានការលូតលាស់ ធំធាត់លឿនជាងមុនខណៈពេលដែលទីធ្លាចិញ្ចឹមមានលក្ខណៈទូលាយជាងមុន ។

### ៨.២ ការប្រមូលផលសរុប

ចំពោះការប្រមូលផលសរុប យើងគួរចាប់ផ្តើមដំណើរការបន្ទាប់ពីការចិញ្ចឹមរយៈពេលពី ៣ ទៅ ៤ខែ ដែលខណៈពេលនេះ ត្រីមានទំហំកាន់តែធំជាមធ្យមទម្ងន់ចាប់ពី ២០០ក្រាម ទៅ ៣០០ក្រាម ក្នុងមួយក្បាល អាចយកទៅលក់

លើទីផ្សារបាន ហើយមានតម្លៃសេដ្ឋកិច្ចខ្ពស់។ ការប្រមូលផលសរុបនេះដើម្បីទទួលបាននូវអត្ថប្រយោជន៍ និងកម្រៃច្រើននោះយើងគួរធ្វើឡើងនៅពេល :

- ត្រីចិញ្ចឹមបានរយៈពេលពី ២ ទៅ ៤ខែ
- ត្រីទម្ងន់ចាប់ពី ១០០ក្រាម ទៅ ៣០០ក្រាម ក្នុង ១ក្បាល
- ប្រមូលផលត្រីនៅរដូវខ្សត់ត្រី ឬ បិទនេសាទ ឬរដូវប្រាំងខ្សត់ត្រីករណីនៅតាមជនបទឆ្ងាយពីដែននេសាទត្រីធម្មជាតិ។
- ជាពិសេស នៅពេលដែលតម្លៃត្រីនៅលើទីផ្សារឡើងដល់កម្រិតខ្ពស់។



*រូបភាពទី០៨: ការប្រមូលផលត្រីអណ្តែងសរុប*

## ១០.ការតាមដាន និងកត់ត្រាទិន្នន័យ

កសិករ វារីវប្បករ ឬអ្នកចិញ្ចឹមត្រីទាំងអស់ ពិសេសកសិករចិញ្ចឹមត្រីអណ្តែងគួរគប្បីឧស្សាហ៍ព្យាយាម ក្នុងការតាមដានមើលថែទាំ គ្រប់គ្រងសកម្មភាពចិញ្ចឹមត្រី និងកត់ត្រាទិន្នន័យជាប្រចាំដើម្បីជាប្រយោជន៍ដ៏មានសារៈសំខាន់សម្រាប់យើងទាំងអស់គ្នា ពីព្រោះថាវានឹងធ្វើឱ្យយើងមានការចងចាំនូវអ្វីដែលយើងបានធ្វើ និងបានអនុវត្ត នៅក្នុងសកម្មភាពចិញ្ចឹមត្រី ជាពិសេសការចំណាយ ចំណូល ដែលទាំងនេះធ្វើឱ្យយើងទទួលបាននូវបទពិសោធន៍ដ៏ល្អៗ សម្រាប់ធ្វើឱ្យប្រសើរឡើងថែមទៀត ក្នុងការចិញ្ចឹមត្រីលើកក្រោយៗទទួលបានទិន្នន័យផលត្រីកាន់តែខ្ពស់។

# តារាងគំរូសម្រាប់កត់ត្រាទិន្នន័យ

## ១០.១ ការទិញកូនត្រីដាក់ចិញ្ចឹម (ទិញកូនត្រី)

ប្រភពកូនត្រីពូជ : ក្នុងមូលដ្ឋាន□ ក្រៅមូលដ្ឋាន□ ស្រុក.....................

ខេត្ត...............................

: ក្រៅស្រុក□ ប្រទេស :.....................................

តារាងទី០១ : ការទិញកូនត្រី

| ល.រ | ថ្ងៃ.ខែ.ឆ្នាំ ទិញកូនត្រី | ចំនួនកូនត្រី (ក្បាល) | ទំហំកូនត្រី (ស.ម/ហ៊ុន) | តម្លៃកូនត្រី (រៀល/ក្បាល) | តម្លៃសរុប (រៀល) |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| | | | | | |

## ១០.២ ការចំណាយ និងចំណូល ក្នុងការចិញ្ចឹមត្រី

តារាងទី០២ : ការចំណាយក្នុងការចិញ្ចឹម

| ល.រ | ថ្ងៃ.ខែ.ឆ្នាំ | មុខចំណាយ | ឯកត្តា | តម្លៃរាយ (រៀល) | តម្លៃសរុប (រៀល) |
|---|---|---|---|---|---|
| ១ | | កូនត្រីពូជ | ក្បាល | | |
| ២ | | ថ្លៃដឹកជញ្ជូនកូនត្រី | | | |
| ៣ | | សាំងបូមទឹក | លីត្រ | | |
| ៤ | | កៅស៊ូប្លាស្ទិក | ម៉ | | |
| ៥ | | ស្បៃហាប៉ាសំរាប់ធ្វើរបាំង | ម៉ | | |
| ៦ | | ចំណី (ករណីទិញ) | គ.ក្រ | | |
| ៧ | | ចំណាយផ្សេងៗ | | | |

តារាងទី០៣ ៖ ប្រាក់ចំណូលបានពីការលក់ត្រី

| ល.រ | ថ្ងៃ.ខែ.ឆ្នាំ | មុខចំណូល | ឯកត្តា | តម្លៃរាយ (រៀល) | តម្លៃសរុប (រៀល) |
|---|---|---|---|---|---|
| ១ | | ត្រីបានចាប់ហូបក្នុងគ្រួសារ | គ.ក្រ | | |
| ២ | | ត្រីបានចាប់លក់ | គ.ក្រ | | |
| ៣ | | ត្រីបានចាប់ចែកជូនអ្នកជិតខាង | គ.ក្រ | | |
| សរុប | | | | | |

## ១០.៧ ការប្រមូលផលត្រីសរុប

តារាងទី០៤ ៖ ការប្រមូលផលត្រី

| ថ្ងៃ.ខែ.ឆ្នាំ | ទម្ងន់ត្រីជាមធ្យម (ក្រោម/ក្បាល) | ទម្ងន់ត្រីសរុប (គ.ក្រ) | តម្លៃរាយ (រៀល) | តម្លៃសរុប (រៀល) |
|---|---|---|---|---|
| | | | | |
| | | | | |

## ឯកសារយោង


- អ៊ូច ឡង់ ១៩៩៥ បច្ចេកទេសផលិតកូនត្រីពូជ អណ្តែងកូនកាត់ (សារណាបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ) មហាវិទ្យាល័យវារីវប្បកម្ម នៃសាកលវិទ្យាល័យជលផលញ៉ាត្រាង ទីក្រុងញ៉ាត្រាង ប្រទេសវៀតណាម។
- អ៊ូច ឡង់ ១៩៩៧ មេរៀនទ្រឹស្តី ស្តីពីបច្ចេកទេសសង្កត់ភ្ញាស់ត្រីអណ្តែងកូនកាត់លក្ខណៈគ្រួសារ
- អ៊ូច ឡង់ ២០០៥ មេរៀនទ្រឹស្តី ស្តីពីបច្ចេកទេសចិញ្ចឹមត្រីអណ្តែងកូនកាត់ជាលក្ខណៈគ្រួសារ
- OUCH Lang, 2008. Technical Information of Hybrid Catfish culture has been using in Cambodia. Phnom Penh, Cambodia.
- Bach Thi Quynh Mai, 1994. Ky Thuat nuoi ca tre vang lai, Nha Xuat Ban Nong Nghiep, Vietnam
- Ngo Trong Lu & Le Dang Khuyen, 2006. Ky Thuat nuoi ca tre, luon, giun dat, Nha Xuat Ban Nong Nghiep, Ha Noi, Vietnam
- Nguyen Duy Khoat, 2005. Ky Thuat nuoi ca tre, ech dong, ba ba, Nha Xuat Ban Nong Nghiep, Ha Noi, Vietnam



រៀបរៀងដោយ : នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល

ឧបត្ថម្ភបោះពុម្ពដោយ : Project Code: 11-PR1-0795

ព័ត៌មានបន្ថែមសូមទំនាក់ទំនងនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល
អគារលេខ ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៨៣៥ ទូរស័ព្ទ/ទូរសារ ៨៥៥ ២៣ ៩៩៦ ៣៨០
អ៊ីម៉ែល : chinda77@yahoo.com